អង្គភាពសវនកម្មផ្ទៃក្នុង
INTERNAL AUDIT UNIT

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទបង្ហាញស្តីពី
# និន្នាការទូទៅនៃការគ្រប់គ្រងប្រតិបត្តិការ

ដោយលោក ទៀន គុយអេង ប្រធានការិយាល័យផែនការ និងបណ្តុះបណ្តាល

ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣

# មាតិកា

១.និយមន័យ

២.គោលបំណងនៃការគ្រប់គ្រងប្រតិបត្តិការ

៣.គោលដៅនៃការគ្រប់គ្រងប្រតិបត្តិការ

៤.ផលប្រយោជន៍នៃការគ្រប់គ្រងប្រតិបត្តិការ

៥.ការចំណាយចំពោះការគ្រប់គ្រងប្រតិបត្តិការ

៦.បញ្ហាប្រឈមចំពោះការអនុវត្តការគ្រប់គ្រងប្រតិបត្តិការ

# ១. និយមន័យ

## ក. ការគ្រប់គ្រង

ការគ្រប់គ្រង គឺជាវិធីសាស្ត្រក្នុងការប្រើប្រាស់ធនធាន ឬការចាត់ចែងធនធានឱ្យអស់ពីលទ្ធភាពដើម្បីសម្រេចបាននូវគោលដៅជាក់លាក់ណាមួយរបស់ស្ថាប័ន ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ការគ្រប់គ្រងមានមុខងារសំខាន់ៗដូចខាងក្រោម÷

១. ការរៀបចំផែនការ

២. ការរៀបចំចាត់ចែង

៣. ការដឹកនាំ

៤. ការតាមដានត្រួតពិនិត្យ។



# ១. និយមន័យ (ត)

## ខ. ប្រតិបត្តិការ

ប្រតិបត្តិការ សំដៅដល់មុខងារប្រតិបត្តិការស្នូលរបស់ស្ថាប័នមួយដែលមុខងារប្រតិបត្តិការសំដៅដល់សកម្មភាពទាំងឡាយណាដែលផ្តោតលើការផលិតទំនិញ ឬសេវាកម្ម។ មុខងារប្រតិបត្តិការរាប់បញ្ចូលដំណើរការក្នុងការបំលែងវត្ថុធាតុដើមទៅជាផលិតផលសម្រេច។ក្នុងន័យទូទៅប្រតិបត្តិការសំដៅដល់ដំណើរការសកម្មភាពណាមួយដែលស្ថាប័នអនុវត្តដើម្បីសម្រេចបាននូវលទ្ធផលជាក់លាក់មួយ។



# ១. និយមន័យ (ត)

## គ. ការគ្រប់គ្រងប្រតិបត្តិការ

ការគ្រប់គ្រងប្រតិបត្តិការ សំដៅទៅលើការគ្រប់គ្រងការអនុវត្តរបស់ស្ថាប័នដើម្បីទទួលបាននូវកម្រិតប្រសិទ្ធភាព និងប្រសិទ្ធផលអតិបរមាទាក់ទងនឹងការប្រើប្រាស់ធនធាន។ ការគ្រប់គ្រងប្រតិបត្តិការ គឺពាក់ព័ន្ធនឹងសកម្មភាពការសម្រេចចិត្ត និងទំនួលខុសត្រូវរបស់អ្នកគ្រប់គ្រងស្ថាប័ន ដើម្បីធានាថាផលិតផល និងសេវាដែលស្ថាប័នបានផ្តល់ជូនអតិថិជនមានគុណភាព និងមានអត្ថប្រយោជន៍ខ្ពស់។



# ១. និយមន័យ (ត)

ភារកិច្ចសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងប្រតិបត្តិការ រួមមាន÷

១. ការតាមដានត្រួតពិនិត្យការអនុវត្តរបស់មន្ត្រីទទួលបន្ទុកអនុវត្តការងារ

២. ការបញ្ជូនការណែនាំនិងការសម្រេចចិត្តពីថ្នាក់ដឹកនាំទៅមន្ត្រីទទួលបន្ទុកអនុវត្តការងារ

៣. ការធានាគុណភាព

៤. ការកាត់បន្ថយហានិភ័យ



# ២. គោលបំណងនៃការគ្រប់គ្រងប្រតិបត្តិការ

គោលបំណងនៃការគ្រប់គ្រងប្រតិបត្តិការ គឺដើម្បីលើកកម្ពស់អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃ។



# ២. គោលបំណងនៃការគ្រប់គ្រងប្រតិបត្តិការ (ត)

**ក. ប្រសិទ្ធភាព**

ប្រសិទ្ធភាព សំដៅទៅដល់ការសម្រេចបាននូវគោលដៅ និងគោលបំណងរបស់ស្ថាប័ន ដោយប្រើប្រាស់ធនធានដែលបានកំណត់ ព្រមទាំងទទួលបានលទ្ធផលដែលរំពឹងទុក។

- ❑ លទ្ធផល (Output) សំដៅដល់ផលដែលកើតចេញពីការធ្វើសកម្មភាព ឬអនុវត្តការងារណាមួយ ដោយផលដែលទទួលបាននោះអាចជាផលិតផល ឬសេវាកម្ម
- ❑ សមិទ្ធផល(Outcome) សំដៅដល់ការសម្រេចបាននូវគោលបំណងនៃការអនុវត្តចុងក្រោយដែលស្ថាប័នចង់បាន

ជាទូទៅ លទ្ធផល និងសមិទ្ធផល អាចស្តែងឡើងឱ្យមើលឃើញជាលក្ខណៈ÷**១).រូបី** តាមរយៈការផលិតបាននូវផលិតផល និង**២).អរូបី** តាមរយៈការផ្តល់សេវាប្រឹក្សា ឬតាមរយៈការអភិវឌ្ឍកម្មវិធី Software ផ្សេងៗ។

ដោយឡែកក្នុងលក្ខខណ្ឌមួយចំនួន សមិទ្ធផល អាចទទួលបាន÷ **១).ដោយផ្ទាល់** តាមរយៈអ្នកដែលមកពិគ្រោះឬមកទទួលសេវាប្រឹក្សា និង**២).ដោយប្រយោល** ដល់ស្ថាបន័បន្ទាប់ពីបានយកទ្រឹស្តី ឬបទពិសោធន៍ដែលទទួលបានតាមរយៈអ្នកមកទទួលសេវាប្រឹក្សា ទៅអនុវត្តផ្ទាល់ហើយទទួលបានប្រសិទ្ធភាព។

# ២. គោលបំណងនៃការគ្រប់គ្រងប្រតិបត្តិការ (ត)

**ឧទាហរណ៍÷**

១. មន្ទីរពេទ្យមួយ បានកំណត់គោលដៅថាទទួលព្យាបាលមនុស្សឱ្យបាន ១០០នាក់ ក្នុងរយៈពេល ១ ខែ÷

- ប្រសិនបើព្យាបាលបានមនុស្ស ១០០នាក់ មែន នោះជាលទ្ធផល (Output)
- តើមនុស្ស ១០០នាក់ នោះពិតជាមានសុខុមាលភាពល្អមែនឬទេក្រោយពីការព្យាបាល នោះជា សមិទ្ធផល (Outcome)។

២. ការរៀបចំកម្មវិធីសិក្ខាសាលាបញ្ជ្រាបការយល់ដឹង

- ប្រសិនបើបានរៀបចំការបញ្ជ្រាបការយល់ដឹងមែន នោះជា**លទ្ធផល** (Output)
- សិក្ខាកាមទាំងអស់ពិតជាបានយល់ដឹងច្បាស់នោះហៅថា **សមិទ្ធផល** (Outcome)។

# ២. គោលបំណងនៃការគ្រប់គ្រងប្រតិបត្តិការ (ត)

ប្រសិទ្ធផល សំដៅទៅដល់ការសម្រេចបានទៅដល់គោលដៅអតិបរមាជាមួយនឹងធនធានដែលបានកំណត់ ឬក៏សម្រេចដល់គោលដៅដែលបានកំណត់ដោយប្រើប្រាស់ធនធានតិចជាងធនធានដែលបានកំណត់។ ក្នុងន័យនេះ **ប្រសិទ្ធផល ឬស័ក្តិសិទ្ធភាព** មានន័យថា **ការសម្រេចបានផលខ្ពស់ជាងមុនជាងការរំពឹងទុក ជាមួយនឹងធនធានដែលបានកំណត់ ម្យ៉ាងទៀត ធនធានដដែល (Input) បានផលខ្ពស់ជាងមុន (Output)** ឬក៏ប្រើប្រាស់ធនធានតិចជាងមុនតែសម្រេចគោលដៅដូចគ្នា ឬសម្រេចគោលដៅខ្ពស់ជាងមុន ជាមួយធនធាន ដែលបានកំណត់។



# ២. គោលបំណងនៃការគ្រប់គ្រងប្រតិបត្តិការ (ត)

**ឧទាហរណ៍÷**

**១.** ដីស្រែចំនួន ១ ហិចតា ធ្លាប់តែធ្វើបាន ៣តោន ជារៀងរាល់ឆ្នាំ ប៉ុន្តែនៅក្នុងឆ្នាំនេះ ដីស្រែ ១ ហិចតាដដែល ធ្វើបានរហូតដល់ ៥តោន។ ម្យ៉ាងទៀត កសិករចំនួន ១០នាក់ ធ្វើស្រែបាន ១០តោន ឥឡូវកសិករចំនួន ៧នាក់ ធ្វើស្រែបាន ១០តោនដូចគ្នា។

**២.** ការរៀបចំចុះត្រួតពិនិត្យក្រុមហ៊ុនដល់ទីកន្លែងរបស់និយ័តករ ធ្លាប់តែចុះត្រួតពិនិត្យ បាន ២០ក្រុមហ៊ុន ក្នុងមួយឆ្នាំ ដោយអ្នកចុះត្រួតពិនិត្យមានចំនួន ១០ នាក់។ ដោយឡែកនាពេលបច្ចុប្បន្ន និយ័តករបានចុះត្រួតពិនិត្យបាន ២៥ ក្រុមហ៊ុន ក្នុងមួយឆ្នាំ ដោយអ្នកចុះត្រួតពិនិត្យមានចំនួន ១០នាក់ ដដែល។

# ២. គោលបំណងនៃការគ្រប់គ្រងប្រតិបត្តិការ (ត)

ភាពសន្សំសំចៃ គឺជាការធ្វើអប្បបរមាថ្លៃដើមនៃធនធាន ដែលធនធានត្រូវបានប្រើប្រាស់គួរតែមានក្នុងកំឡុងពេលកំណត់មួយ ប្រកបដោយគុណភាព និងបរិមាណសមស្រប ព្រមទាំងមានតម្លៃល្អសមរម្យ។

ទស្សនាទានលើភាពសន្សំសំចៃ បានពន្យល់យ៉ាងច្បាស់ពីការអនុវត្តការងារប្រកបដោយភាពសន្សំសំចៃជារឿងចាំបាច់សម្រាប់ស្ថាប័នសាធារណៈទាំងអស់។ ជារឿយៗ បញ្ហាប្រឈមដ៏លំបាកសម្រាប់ស្ថាប័នសាធារណៈ គឺធ្វើយ៉ាងណាប្រើប្រាស់ថវិកាសាធារណៈប្រកបដោយភាពសន្សំសំចៃ។



# ២. គោលបំណងនៃការគ្រប់គ្រងប្រតិបត្តិការ (ត)

**ឧទាហរណ៍÷** តើស្ថាប័នផ្តល់អាជ្ញាបណ្ណមានភាពសន្សំសំចៃឬទេ លុះត្រាតែសវនករជ្រើសរើសស្ថាប័ន ណាមួយដែលប្រហាក់ប្រហែលគ្នាដែលធ្វើការផ្តល់អាជ្ញាបណ្ណដូចគ្នា ហើយធ្វើការប្រៀបធៀបនឹងគ្នាទៅលើការចំណាយទាបជាង នោះទើបសវនករអាចកំណត់ហានិភ័យបាន។



# ៣. គោលដៅនៃការគ្រប់គ្រងប្រតិបត្តិការ

ការគ្រប់គ្រងប្រតិបត្តិការជាសកម្មភាពទាំងឡាយដែលថ្នាក់ដឹកនាំបង្កើតឡើង ដើម្បីលើកកម្ពស់លទ្ធភាពធានាឱ្យគោលដៅបានកំណត់អាចសម្រេចបាន។ ដូច្នេះការគ្រប់គ្រងប្រតិបត្តិការមានគោលដៅធំៗចំនួន ៣ គឺ÷

- ការបង្កើនប្រសិទ្ធភាព
- ការបង្កើនប្រសិទ្ធផល
- ការបង្កើនភាពសន្សំសំចៃ។



# ៤. ផលប្រយោជន៍នៃការគ្រប់គ្រងប្រតិបត្តិការ (ត)

ការគ្រប់គ្រងប្រតិបត្តិការមានផលប្រយោជន៍ដល់ស្ថាប័នដើម្បីសម្រេចបានការគ្រប់គ្រង និងការអនុវត្តមួយប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលនៅក្នុងមុខងារ និងភារកិច្ចរួមមាន÷

- បង្កើនទំនុកចិត្តពីសាធារណជន
- កាត់បន្ថយជាអតិបរមានូវភាពខ្ជះខ្ជាយ
- បង្កើនផលចំណេញសម្រាប់ស្ថាប័ន។



# ៥. ការចំណាយចំពោះការគ្រប់គ្រងប្រតិបត្តិការ

នៅពេលដែលស្ថាប័នដាក់ឱ្យដំណើរការប្រតិបត្តិការអ្វីមួយ តែងតែទាមទារឱ្យមាននូវការចំណាយលើប្រតិបត្តិការនោះ និងទៅលើការគ្រប់គ្រងប្រតិបត្តិការ ដែលការចំណាយចំពោះការគ្រប់គ្រងប្រតិបត្តិការត្រូវបានបែងចែកជាពីរ (២) ប្រភេទរួមមាន÷

**ក. ចំណាយជាក់ស្តែង**

ចំណាយជាក់ស្តែង សំដៅដល់ចំណាយដែលទ្រទ្រង់ប្រតិបត្តិការរបស់ស្ថាប័នផ្ទាល់រួមមានចំណាយលើរចនាសម្ព័ន្ធស្ថាប័ន ចំណាយប្រាក់បៀវត្សមន្ត្រី ចំណាយលើការរៀបចំប្រព័ន្ធត្រួតពិនិត្យ ចំណាយសម្រាប់ការអនុវត្តសកម្មភាពណាមួយ ចំណាយសម្ភារៈបរិក្ខារ និងចំណាយប្រេង អគ្គិសនី និងទឹក។

# ៥. ការចំណាយចំពោះការគ្រប់គ្រងប្រតិបត្តិការ (ត)

## ខ. ចំណាយឱកាស

ចំណាយឱកាស សំដៅដល់ចំណាយទៅលើជម្រើស ឬឱកាសផ្សេងទៀតដែលត្រូវលះបង់ដើម្បីអាចជ្រើសរើស ឬដាក់ឱ្យប្រតិបត្តិការមួយដំណើរការ។ រាល់ការដាក់ឱ្យដំណើរការប្រតិបត្តិការទាំងអស់តែងតែមាននូវចំណាយឱកាស។ ប្រសិនបើស្ថាប័នពុំដាក់ឱ្យដំណើរការនូវប្រតិបត្តិការណាមួយដែលបានជ្រើសរើសនោះទេ ស្ថាប័នអាចនឹងប្រើប្រាស់ធនធានដែលត្រូវចំណាយនោះលើប្រតិបត្តិការណាផ្សេងទៀត។



# ៦. បញ្ហាប្រឈមចំពោះការអនុវត្តការគ្រប់គ្រងប្រតិបត្តិការ

ក្នុងការអនុវត្តការគ្រប់គ្រងប្រតិបត្តិការ តែងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយពាក់ព័ន្ធនឹង៖

**ក. ធនធានមនុស្ស**

ធនធានមនុស្ស សំដៅដល់កម្លាំងចលករដ៏សំខាន់របស់ស្ថាប័នក្នុងកិច្ចដំណើរការអនុវត្តការងារប្រចាំថ្ងៃ។ ក្នុងស្ថាប័ននីមួយៗ ពាក់ព័ន្ធនឹងផ្នែកធនធានមនុស្ស គេតែងពិនិត្យឃើញនូវបញ្ហាប្រឈមធំៗចំនួន ២ គឺ៖

**១).** បរិមាណ៖ ថាតើមានបុគ្គលិកគ្រប់គ្រាន់សម្រាប់ធ្វើការឬនៅ?

**២).** គុណភាព៖ ថាតើបុគ្គលិកទាំងអស់សុទ្ធសឹងតែមានជំនាញនិងវិជ្ជាជីវៈគ្រប់គ្រាន់សម្រាប់ការអនុវត្តការងារឬនៅ?

ដូច្នេះ ស្ថាប័ន ត្រូវយកចិត្តទុកដាក់បំផុតទៅលើធនធានមនុស្ស ដោយមានការឧបត្ថម្ភលើកទឹកចិត្ត ការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសដើម្បីមានឱកាសទទួលបាននូវបទពិសោធន៍ថ្មីៗ ចំណេះជំនាញច្បាស់លាស់។

# ៦. បញ្ហាប្រឈមចំពោះការអនុវត្តការគ្រប់គ្រងប្រតិបត្តិការ (ត)

**ខ. ជំនាញ**

ជំនាញសំដៅដល់សមត្ថភាពក្នុងការប្រើប្រាស់ចំណេះដឹងប្រកបដោយប្រសិទ្ធភាព និងងាយស្រួលក្នុងការអនុវត្តការងារ។

ដូចនេះ ជំនាញរបស់មន្ត្រីទទួលបន្ទុកអនុវត្តការងារគឺពិតជាមានសារៈសំខាន់ណាស់ដើម្បីជួយការលើកកម្ពស់ដល់ប្រសិទ្ធភាពការងារ តម្រង់ឆ្ពោះទៅរកការសម្រេចបាននូវផែនការរបស់ស្ថាប័ន។

បន្ថែមពីនេះ ការបែងចែកការទទួលបន្ទុករបស់មន្ត្រីនីមួយៗទៅតាមជំនាញរៀងៗខ្លួន គឺជារឿងចាំបាច់បំផុតដើម្បីចៀសវាងភាពយឺតយ៉ាវក្នុងការសម្រេចបាននូវលទ្ធផលការងារស្របទៅតាមផែនការដែលបានកំណត់។



# ៦. បញ្ហាប្រឈមចំពោះការអនុវត្តការគ្រប់គ្រងប្រតិបត្តិការ (ត)

## គ. ប្រព័ន្ធលើកទឹកចិត្តការងារ

ប្រព័ន្ធលើកទឹកចិត្ត សំដៅដល់សំណង ឬការទទួលផលអំពីការខិតខំប្រឹងប្រែងអនុវត្តការងារ។

ប្រព័ន្ធលើកទឹកចិត្ត ជាផ្នែកមួយនៃការលើកកម្ពស់ការលើកទឹកចិត្តដើម្បីជួយជំរុញក្នុងពេលបំពេញមុខងារ និងភារកិច្ចរបស់មន្ត្រីទទួលបន្ទុកអនុវត្តការងារប្រកបដោយគុណភាព ប្រសិទ្ធផល និងប្រសិទ្ធភាពការងាររបស់ស្ថាប័ន។

- ជាទូទៅ ប្រព័ន្ធលើកទឹកចិត្តអាចត្រូវបានធ្វើឡើងក្នុងទម្រង់ជាសំណងហិរញ្ញវត្ថុ និងសំណងមិនមែនហិរញ្ញវត្ថុ ដែលមានដូចជា ការសរសើរ ការតែងតាំង ការតំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការផ្តល់អត្ថប្រយោជន៍ផ្សេងទៀតដល់មន្ត្រីទទួលបន្ទុកអនុវត្តការងារ។



# ៦. បញ្ហាប្រឈមចំពោះការអនុវត្តការគ្រប់គ្រងប្រតិបត្តិការ (ត)

## ឃ. បរិស្ថានការងារ

បរិស្ថានការងារ សំដៅដល់លក្ខខណ្ឌការងារ និងលក្ខខណ្ឌផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងការងាររួមបញ្ចូលទាំងទីកន្លែងការងារ សម្ភារៈប្រើប្រាស់ និងបុគ្គលជាប់ពាក់ព័ន្ធ ផ្សេងៗទៀត។

ប្រសិនបើស្ថាប័នមួយមាននូវបរិស្ថានការងារល្អ មាននូវទីកន្លែងសម្រាប់បំពេញការងារសមស្រប មានផាសុកភាព ហើយមានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ ព្រមទាំងមានក្រុមការងារប្រកបដោយស្មារតីក្រុម និងទទួលខុសត្រូវនោះពិតជារួមចំណែកយ៉ាងសំខាន់ដល់ស្ថាប័នក្នុងការសម្រេចបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួន។



# ៦. បញ្ហាប្រឈមចំពោះការអនុវត្តការគ្រប់គ្រងប្រតិបត្តិការ (ត)

**ង. ឆន្ទៈ**

ឆន្ទៈ សំដៅដល់ការប្តេជ្ញាចិត្តក្នុងការសម្រេចបាននូវសកម្មភាពការងារណាមួយ។

ឆន្ទៈរបស់មន្ត្រីទទួលបន្ទុកអនុវត្តការងារ គឺជារឿងដ៏សំខាន់ក្នុងការជួយជម្រុញឱ្យការងាររបស់ស្ថាប័នបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

មន្ត្រីអនុវត្តការងារ ត្រូវមានស្មារតីក្នុងការបំពេញការងារ និងការទទួលខុសត្រូវខ្ពស់ ក្នុងន័យថាមន្ត្រីអនុវត្តការងារត្រូវបង្ហាញនូវភាពជាម្ចាស់ការលើការងារដែលខ្លួនទទួលខុសត្រូវដោយអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត។



# ៦. បញ្ហាប្រឈមចំពោះការអនុវត្តការគ្រប់គ្រងប្រតិបត្តិការ (ត)

## ច. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សំដៅសំណុំនៃសមាសធាតុ (Interconnected Component) ឬជាប្រព័ន្ធដែលបង្កើតឡើងសម្រាប់ជួយសម្រួលដល់ការអនុវត្តការងាររបស់ស្ថាប័នប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍស្ថាប័ន និងជួយសម្រួលដល់ការដាក់ឱ្យដំណើរការប្រតិបត្តិការស្ថាប័ន និងកិច្ចដំណើរការការគ្រប់គ្រងប្រតិបត្តិការ។

ការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មាន បានផ្ដល់ផលប្រយោជន៍ជាសក្ដានុពលជាច្រើនដល់ស្ថាប័ន ក៏ប៉ុន្តែនៅតែមានហានិភ័យដោយសារប្រយោជន៍នៃបច្ចេកវិទ្យាទាំងនេះបានផ្ដល់ឱ្យតែស្ថាប័នណាដែលមានលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តតែប៉ុណ្ណោះ។ ដូចនេះ ស្ថាប័នត្រូវយកចិត្តទុកដាក់ទៅលើការរីកចម្រើននៃប្រព័ន្ធបច្ចេកវិទ្យាថ្មីៗ ដើម្បីអាចសម្របខ្លួនចាប់យកប្រព័ន្ធបច្ចេកវិទ្យាថ្មីៗទាំងនោះ និងអាចមានជំនាញ និងលទ្ធភាពគ្រប់គ្រាន់អាចប្រើប្រាស់បាន។

# ៦. បញ្ហាប្រឈមចំពោះការអនុវត្តការគ្រប់គ្រងប្រតិបត្តិការ (ត)

## ឆ. បច្ចេកទេសក្នុងការអនុវត្តការងារ

បច្ចេកទេសក្នុងការអនុវត្តការងារ សំដៅដល់វិធីសាស្រ្ត ឬរបៀបនៅក្នុងការអនុវត្តការងារប្រចាំថ្ងៃ។

បច្ចេកទេសក្នុងការអនុវត្តការងារ អាចត្រូវបានរៀបចំឡើងជា សេចក្តីណែនាំ គោលការណ៍ណែនាំ ប្រកាស ឬបទដ្ឋានការងារផ្សេងទៀតដើម្បីធានាបាននូវភាពត្រឹមត្រូវនិងសមស្របក្នុងការអនុវត្តការងារ។

ការកង្វះខាតនូវបច្ចេកទេសក្នុងការអនុវត្តការងារ អាចបណ្តាលឱ្យមានភាពយឺតយ៉ាវ និងខ្វះចន្លោះ ដែលនាំឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពក្នុងការអនុវត្តការងារផងដែរ។



# សូមអរគុណ

# THANKS FOR YOUR ATTENTION

អង្គភាពសវនកម្មផ្ទៃក្នុង
INTERNAL AUDIT UNIT

Facebook

Telegram

www.iauoffsa.gov.kh

អាគារ ១៦៨F ជាន់ទី៩ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

